**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ម្ចាស់ ឬនាយកក្រុមហ៊ុន៖ ថេកណូផាក ប៉ោយ ប៉ែត ភីធីអី ខូអិលធីឌី**
លេខបញ្ជីពាណិជ្ជកម្ម៖ MOC-៩១៥១៦៨៤៣ ពណ.ចបព.
លេខអត្តសញ្ញាណសហគ្រាសក្នុង ប.ស.ស.៖ ១០០៨៨៧៦
លេខគណនីធនាគារ៖ ៣៤៣៨០១៨៤២២៦១១១ (ធននាគារអេស៊ីលីដា)
អាសយដ្ឋាន៖ ភូមិ ផ្សារកណ្តាល ឃុំ/សង្កាត់ ផ្សារកណ្តាល ក្រុង/ស្រុក/ខណ្ឌ ក្រុងប៉ោយប៉ែត រាជធានី/ខេត្ត បន្ទាយមានជ័យ
ទូរស័ព្ទលេខ៖០១១ ៦៥៥៥ ៧៥ អ៊ីមែល (E-mail)៖ yam_thouchhing@technopark.com.kh

**សូមគោរពជូន**
**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**តាមរយៈ៖** លោកប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តបន្ទាយមានជ័យ
**កម្មវត្ថុ ៖** សំណើសុំ អនុញ្ញាតឲ្យកម្មករនិយោជិត ចំនួន ៦៥នាក់ឲ្យចូលធ្វើការមុនពេលរយៈពេលព្យួរកិច្ចសន្យាការងារ ៦០ថ្ងៃ

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាជ្រាបថា ដោយមូលហេតុក្រុមហ៊ុនយើងខ្ញុំចាប់ផ្តើមមានការបញ្ជាទិញឡើងវិញ ដូច្នេះក្រុមហ៊ុនយើងខ្ញុំស្នើសុំកម្មករនិយោជិត ចំនួន ៦៥ នាក់ (ស្រី ៥៥នាក់)ឲ្យចូលបម្រើការងារឡើងវិញ ក្នុងចំណោមកម្មករនិយោជិតដែលបានព្យួរកិច្ចសន្យាការងារសរុបចំនួន១៧៧នាក់រយៈពេលនៃការព្យួរកិច្ចសន្យាការងារចំនួន៦០ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២០។ ដោយសុំអនុញ្ញាតឲ្យកម្មករនិយោជិត ចំនួន៦៥នាក់ ចូលបម្រើការងារចាប់ផ្តើមពីថ្ងៃទី២៧ ខែ កក្កដា ឆ្នាំ ២០២០។

ក្នុងកំឡុងពេលចាប់ផ្តើមអនុញ្ញាតឲ្យកម្មរនិយោជិត៦៥នាក់ចូលបម្រើការងារឡើងវិញ ក្រុមហ៊ុននិង កម្មករនិយោជិតបានព្រមព្រៀងឲ្យក្រុមហ៊ុនផ្តល់ប្រាក់ឧបត្ថម្ភជូនដល់កម្មករនិយោជិតដូចដើមសម្រាប់ប្រាក់ខែគោល ១០០% ថ្លៃស្នាក់នៅ ១០០% ប្រាក់ឧបត្ថម្ភធ្វើដំណើរ១០០% និងអត្ថប្រយោជន៍ផ្សេងៗទៀត ក្រុមហ៊ុនផ្តល់នឹងជូនកម្មករនិយោជិត ទៅតាមច្បាប់ ឬគោលការណ៍ណែនាំ របស់ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជីវៈ នៃព្រះរាជណាចក្រកម្ពុជា។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាពិនិត្យ និងសម្រេចដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

បន្ទាយមានជ័យ ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ២០២០
ហត្ថលេខា និងត្រា
ម្ចាស់ ឬនាយក

ព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុន ថេកណូផាក ប៉ោយប៉ែត ភីធីអី ខូ អិលធីឌី Techno Park Poi Pet Pvt Co.,Ltd. KINGDOM OF CAMBODIA

ណៅតូ ស៊ូហ្គិតាគីតា
NAOTO SUGITA

**សូមភ្ជាប់មកជាមួយ:**
- លិខិតអនុញ្ញាតស្នើសុំឲ្យកម្មករនិយោជិតចូលធ្វើការចំនួន ១ច្បាប់
- បញ្ជីរាយនាមកម្មករនិយោជិតដែលស្នើសុំចូលធ្វើការងារ ១ ច្បាប់
- Soft Copy (Ms Excel) ទៅ E-mail: suspension@nea.gov.kh